ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៣៤/១៤-ហារតា ផេកខេជីង

កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ហារតា ផេកខេជីង អ៊ីនដាស្ត្រី (ខេមបូឌា) លីមីតធីត**

អាសយដ្ឋាន ៖ ភូមិអង្គ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៦២៦ ៨៦២ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមផ្តល់ព័តមានលំអិត ៖

- លោក ហំ ភា មេធាវី

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពជាតកម្មករកម្ពុជា**

អាសយដ្ឋាន ៖ ផ្លូវជាតិលេខ៣ សួនឧស្សាហកម្មវ៉ឹឌ្បនៈ២ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១៧ ៨៥៥ ៥៣៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមផ្តល់ព័តមានលំអិត ៖

១- លោក តុល ផាន់មឿង ប្រធានសហព័ន្ធសហជីពជាតិកម្មករកម្ពុជា

២- លោក ប៉ាង ចន្ទី ប្រធានសហព័ន្ធសហជីពកម្មករខ្មែរ

| | |
|---|---|
| ៣- លោក ដេវ ឡេន | មន្ត្រីសហព័ន្ធសហជីពជាតិកម្មករកម្ពុជា |
| ៤- កញ្ញា វ៉ែន ស្រីល័ក្ខ | មន្ត្រីសហព័ន្ធសហជីពជាតិកម្មករកម្ពុជា |
| ៥- លោក ស៊ន បូរ៉ា | ប្រធានសហជីពជាតិកម្មករកម្ពុជាប្រចាំរោងចក្រ |
| ៦- លោក ឈុន វង្ស | តំណាងកម្មករ |
| ៧- លោក ង៉ែត វណ្ណា | កម្មករផ្នែកត្រួតពិនិត្យគុណភាព |
| ៨- លោក ឡេង លឿន | កម្មករផ្នែកត្រួតពិនិត្យគុណភាព |
| ៩- លោក ដៀត សំអាង | កម្មករផ្នែកត្រួតពិនិត្យគុណភាព |
| ១០- លោក ដុំ សម្បត្តិ | កម្មករផ្នែកឃ្លាំង |
| ១១- លោក ផា មួន | មេការ |
| ១២- លោក ងុយ សារិទ្ធ | ប្រធានផ្នែកផលិត |
| ១៣- លោក ស៊ន ពុទ្ធា | ប្រធានផ្នែក |
| ១៤- លោក ថាច ចាន់ថា | ជាង |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់បំណាច់ផ្សេងៗតាមច្បាប់ស្តីពីការងារព្រោះពីឆ្នាំ២០០៤ ដល់ ២០១២ ថៅកែក្រុមហ៊ុនជាជនជាតិម៉ាឡេស៊ី និងពីឆ្នាំ២០១២ មកដល់បច្ចុប្បន្ន ថៅកែក្រុមហ៊ុនជាជនជាតិជប៉ុន។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចទូទាត់ប្រាក់បំណាច់ផ្សេងៗជូនកម្មករនិយោជិតបានឡើយ ព្រោះក្រុមហ៊ុនពុំបានបញ្ឈប់ពួកគាត់បានទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ១៥៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជាទីងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១៧០ កប/អក/វក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤។

THE ARBITRATION COUNCIL

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទកិច្ចប្រជុំមុនសវនាការ** ៖ - ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ (វេលាម៉ោង ១៦ និង ៣០ នាទី រសៀល ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងតាមទូរស័ព្ទពីកម្មករនិយោជិត ស្តីពីការធ្វើកូដកម្មទាមទារសុំឱ្យក្រុមហ៊ុនទូទាត់ប្រាក់បំណាច់ផ្សេងៗតាមច្បាប់ស្តីពីការងារ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ ដល់ទីតាំងក្រុមហ៊ុន និងធ្វើការផ្សះផ្សា នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ទៅលើការទាមទារចំនួន ០១ ចំណុច។ ចំណុចមិនសះជាចំនួន ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ហារតា ផេកខេជីង អ៊ិនដាសស្ទ្រី (ខេមបូឌា) លីមីតធីត លេខ ១៧០ កប/អក/វក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤។

កម្មករនិយោជិតបានបន្តធ្វើកូដកម្ម បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលលិខិត លេខ ០២០ គួរី/១៤ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ការិយាល័យមេធាវី គួរី ដែលមានមេធាវី ហំ ភា ជាមេធាវីតំណាងដោយអាណត្តិឱ្យក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាស់ស្ទ្រី (ខេមបូឌា) លីមីធីត ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាស់ស្ទ្រី (ខេមបូឌា) លីមីធីត ដែលចាប់ផ្តើមពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០០៦/១៤ កបអ. ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាស់ស្ទ្រី (ខេមបូឌា) លីមីធីត រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ តទៅតាមវេនរបស់ខ្លួន។ ផ្ទុយទៅវិញ កូដករនៅតែបន្តធ្វើកូដកម្មដដែល ដោយមិនបានគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤ នៅវេលាម៉ោង ១៦៖៣០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមានតាមការអញ្ជើញ។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសាកសួរភាគីអំពីបញ្ហាការឈប់ធ្វើកូដកម្មរបស់ភាគីកម្មករនិយោជិត និងការអនុញ្ញាតរបស់ភាគីនិយោជកឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញតាមវេនរៀងៗខ្លួន។ ភាគីកម្មករនិយោជិតបានលើកឡើងថា កម្មករនិយោជិតយល់ព្រមចូលធ្វើការវិញតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏ប៉ុន្តែ និយោជកមិនបានអនុញ្ញាតឱ្យកម្មករនិយោជិតពីររូប រួមមាន កម្មករ ស៊ន បូរ៉ា ជាប្រធានសហជីពជាតិកម្មករកម្ពុជាប្រចាំរោងចក្រ និងកម្មករ ស៊ួន ពុទ្ធា ជាប្រធានផ្នែកផលិតកម្ម ក្នុងចំណោមកូដករទាំងអស់ចូលធ្វើការវិញទេ ដោយសារនិយោជកបានព្យួរកិច្ចសន្យា

ការងាររបស់ពួកគាត់តាំងពីថ្ងៃទីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ (មួយថ្ងៃបន្ទាប់ពីកូដកម្ម) ក្រោមការចោទប្រកាន់ពីបទញុះញង់កម្មករនិយោជិតធ្វើកូដកម្ម។ ភាគីកម្មករនិយោជិតបានបន្តថា និយោជកបានបំពានទឹងដីកាសម្រេចរក្សាការពារ របស់សាលាដំបូងរាជធានីភ្នំពេញ និងសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រោះដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ និងសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល បង្គាប់ឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការងារវិញ ដោយមិនបានកំណត់ឱ្យនិយោជកព្យួរកិច្ចសន្យាការងាររបស់ កម្មករ ស៊ន បូរ៉ា និងកម្មករ ស៊ន ពុទ្ធា នោះទេ។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កូដករបានបន្តធ្វើកូដកម្មវិញ និង នឹងមិនបញ្ឈប់កូដកម្មទេ ប្រសិនបើនិយោជកមិនអនុញ្ញាតឱ្យ កម្មករ ស៊ន បូរ៉ា និងកម្មករ ស៊ន ពុទ្ធា ចូលធ្វើការវិញ។

ចំណែកឯ ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនអាចឱ្យ កម្មករ ស៊ន បូរ៉ា និងកម្មករ ស៊ន ពុទ្ធា ចូលធ្វើការវិញនោះទេ ព្រោះកម្មករទាំងពីរនាក់បានប្រព្រឹត្តិកំហុសធ្ងន់ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។ ដូចនេះ និយោជកសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់ កម្មករ ស៊ន បូរ៉ា និងកម្មករ ស៊ន ពុទ្ធា នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០១៤ ដើម្បីរង់ចាំសេចក្តីសម្រេចពីអធិការការងារ។

ក្រោយពីស្តាប់ហេតុផលរបស់ភាគីទាំងពីររួចមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានស្នើឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញតាមវេនវៀង៧ខ្លួន និងស្នើឱ្យនិយោជកអនុញ្ញាតឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការវិញតាមវេនវៀង៧ ខ្លួនដែរ ដើម្បីទុកលទ្ធភាពឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តនីតិវិធីដោះស្រាយវិវាទទាំងនេះ តាមច្បាប់ស្តីពីការងារ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទុកពេលឱ្យភាគីទាំងពីរធ្វើការពិចារណា រកដំណោះស្រាយដើម្បីឱ្យកម្មករនិយោជិតចូលធ្វើការវិញ ត្រឹមថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ វេលាម៉ោង ១១៖០០ នាទី ព្រឹក។

នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ វេលាម៉ោងប្រហែលជា ១៤៖០០ នាទី រសៀល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលពតិមានតាមរយៈទូរស័ព្ទពីភាគីទាំងពីរថា កម្មករនិយោជិត នៃក្រុមហ៊ុន ហារតា ផេកខេជីង អ៊ីនដាស្រ្ទី (ខេមបូឌា) លីមីតធីត នៅតែបន្តធ្វើកូដកម្មដដែល។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម៖

**តស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖គ្មាន**

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់នាយកគ្រប់គ្រងក្រុមហ៊ុន ហារតា ផាកខេជីង ប្រគល់សិទ្ធិជូនលោកមេធាវី ហ៊ំ ភា ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤។

២- លិខិតលេខ ០២០ គួរី/១៤ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ របស់មេធាវី ហ៊ំ ភា គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជាដើម្បីផ្អាកការធ្វើកូដកម្មរបស់របស់កម្មករនិយោជិតនៅក្រុមហ៊ុន ហារតា ផាកខេជីង អ៊ិនដាស់ស្ត្រី (ខេមបូឌា) លីមីធីត។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហារតា ផេកខេជីង អ៊ីនដាស្ទ្រី (ខេមបូឌា) លីមីតធីត លេខ ១៧០ កប/អក/វក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ហារតា ផេកខេជីង អ៊ីនដាស្ទ្រី (ខេមបូឌា) លីមីតធីត ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក លោកប្រធានសហព័ន្ធសហជីពជាតិកម្មករកម្ពុជា ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល លេខ ១៨៣ កប/អក/វក/លកអ. ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤។

២- សេចក្តីបញ្ជោរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០៦/១៤ កបអ. ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័តមានលំអិត លេខ ១៨៧ កប/អក/វក/លកអ. ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួម ផ្តល់ព័តមានលំអិត លេខ ១៨៨ កប/អក/វក/លកអ. ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៤។

**អង្គហេតុ**

មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចវិវាទ នៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចដំណើរការទៅបាន។

**ហេតុផលនៃសេចក្តីសម្រេច ៖**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"*។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល ។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៥៩/០៦-សាង វ៉ូ ,លេខ៣៩/០៨-ចុង យ៉ូវ, លេខ ១៣៧/០៩, ១៣៨/០៩-ញ៉ូ ភាញ់, លេខ ១០៣/១០-វ៉ាយចិច, លេខ ១១០/១១-ស៊ីម៉ាណូ, លេខ ១០៤/១៣-សាប្រ៊ីណា (ខេមបូឌា), និង លេខ ០១៩/១៤-ដុងឌូ ថេកស្តាយ (ខេមបូឌា))* ។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ កំណត់ថា ៖

*“ ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម ”*។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ប្រ៉ែគ្គិ អង្គរ,សាន់វេ, អ៊ិនធើខនធីណេនថល និង សូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០៤ ត្រង់ចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះចែងដូចខាងក្រោម ៖

*“ ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬ ការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ ”* ។

*“ ចំណុចទី ១១-ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ ”* ។

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ប្រ៉ូង់កូ នីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើកូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ ។

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ និងសំណុំរឿងលេខ ១៧/១៣-អ៊ិនធើណាស្យូណាល់ ហ្វេស៊ិនរ៉ូយ៉ាល់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្មក្នុងអំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ ។

ចំណែកឯ នៅក្នុងសំណុំរឿងលេខ ៤៩/១០-វីង យីង វិញ និយោជកបានសម្រេចបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងអស់ក្នុងរោងចក្រ បន្ទាប់ពីក្រុមអាជ្ញាកណ្តាលចេញសេចក្តីបញ្ជាឱ្យភាគីកម្មករនិយោជិតផ្អាកកូដកម្ម នៅក្នុងដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនោះ បានចាត់ទុកថា

THE ARBITRATION COUNCIL

ការបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងអស់នៅក្នុងរោងចក្រក្នុងដំណើរការអាជ្ញាកណ្តាល ជាវិធានការដទៃទៀតរបស់និយោជក ដែលធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ដោយផ្អែកលើហេតុផលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាល ដោយយោងតាមប្រការ ២០ ខាងលើ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របតាមការសម្រេច របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះហៅភាគីទាំងពីរមកបំភ្លឺលើករណីកូដកម្មនេះ ក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាលនាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤ នៅវេលាម៉ោង ១៦៖៣០ នាទីរសៀល។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ជាដំបូង កូដករបានយល់ព្រមចូលធ្វើការវិញតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០០៦/១៤ កបអ. ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ ហើយ។ ផ្ទុយទៅវិញ ភាគីនិយោជកមិនបានអនុញ្ញាតឱ្យកូដករពីររូប គឺ កម្មករ ស៊ិន បូរ៉ា និងកម្មករ ស៊ិន ពុទ្ធា ដែលនិយោជកបានព្យួរកិច្ចសន្យាការងារក្រោយពីកូដកម្មបានកើតឡើងមួយថ្ងៃ ចូលធ្វើការវិញទេ។ ហេតុនេះ កូដករបានធ្វើកូដកម្មវិញ និង បានបញ្ជាក់ថាពួកគាត់នឹងមិនបញ្ឈប់កូដកម្មទេ ប្រសិនបើនិយោជកមិនអនុញ្ញាតឱ្យកូដករពីររូបនេះ ត្រឡប់ចូលធ្វើការវិញ។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា និយោជកបានបំពាននឹងដីកាសម្រេចរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ និងសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលបង្គាប់ឱ្យកម្មករនិយោជិតទាំងអស់ចូលធ្វើការងារវិញ ដោយមិនបានកំណត់ឱ្យ និយោជកព្យួរកិច្ចសន្យាការងាររបស់ កម្មករ ស៊ិន បូរ៉ា និងកម្មករ ស៊ិន ពុទ្ធា នោះទេ។ ចំណែកឯ ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនអាចឱ្យ កម្មករ ស៊ិន បូរ៉ា និងកម្មករ ស៊ិន ពុទ្ធា ចូល ធ្វើការវិញទេ ព្រោះកម្មករទាំងពីរនាក់បានប្រព្រឹត្តិកំហុសធ្ងន់ ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ហើយការព្យួរកិច្ចសន្យាការងាររបស់ កម្មករ ស៊ិន បូរ៉ា និងកម្មករ ស៊ិន ពុទ្ធា គឺដើម្បីរង់ចាំសេចក្តីសម្រេចពីអធិការការងារ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកបានចាត់វិធានការដទៃទៀត ដែលធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ តាមរយៈការព្យួរកិច្ចសន្យាការងារកូដករពីររូបបន្ទាប់ពីកូដកម្មបានកើតឡើង និង មិនព្រមអនុញ្ញាតឱ្យពួកគាត់ទាំងពីរចូលធ្វើការវិញ បន្ទាប់ពីមានសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ វិធានការនេះបានបង្កឱ្យកូដករត្រឡប់ទៅធ្វើកូដកម្មវិញ ព្រមទាំងប្រកាន់ជំហរមិនបញ្ឈប់កូដកម្មទេ ប្រសិនបើ និយោជកមិនអនុញ្ញាតឱ្យកូដករពីររូបនេះ ត្រឡប់ចូលធ្វើការវិញ។

ដូចនេះ ដោយផ្អែកតាមប្រការ ២០ នៃប្រកាស ០៩៩ ខាងលើ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗពាក់ព័ន្ធនឹងប្រការ ២០ នេះ (ករណីកូដកម្ម ឡុកអៅ និងការចាត់វិធានការវិវាទដទៃទៀត ដែលធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះទេ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ។

THE ARBITRATION COUNCIL

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## **សម្រេច និង បង្គាប់**

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៣៤/១៤-ហារតា ផេកខេជីង ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល**

ឈ្មោះ ៖ **ម៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL